**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**បេឡាជាតិរបបសន្តិសុខសង្គម**

លេខៈ ០១៥/១៥ ប.ស.ស

# សេចក្តីជូនដំណឹង

បេឡាជាតិរបបសន្តិសុខសង្គម(ប.ស.ស)មានកិត្តិយសសូមជម្រាបជូនដំណឹងដល់លោក/លោកស្រី ជាម្ចាស់ ឬនាយក ឬតំណាងនៃសហគ្រាសគ្រឹះស្ថាន ព្រមទាំងសាមីជនរងគ្រោះទាំងអស់ជ្រាបថា ប.ស.ស បានពិនិត្យឃើញថាមានសហគ្រាសគ្រឹះស្ថាន ជាច្រើនបានជូនដំណឹងអំពីគ្រោះថ្នាក់ការងារ ដែលធ្លាក់មកលើកម្មករនិយោជិតរបស់ខ្លួននៅក្នុងឆ្នាំ ២០១៥ នេះ ហើយមានសហគ្រាស គ្រឹះស្ថាន ឬសាមីជនរងគ្រោះថ្នាក់ការងារខ្លះបានបំពេញបែបបទទាមទារ និងទទួលបាន**តាវកាលិក**រួចហើយ។ ប៉ុន្តែនៅមានសហគ្រាស គ្រឹះស្ថាន ឬសាមីជនរងគ្រោះថ្នាក់ការងារជាច្រើនទៀតពុំទាន់បានទទួល **តាវកាលិក** ដែលមានដូចជាៈ

- **-តាវកាលិកព្យាបាល** (សោហ៊ុយសម្រាប់ការព្យាបាលដែលសាមីជនរងគ្រោះ ឬអ្នកតំណាងបានចំណាយជាមុន)
- **-តាវកាលិកថែទាំ** (ប្រាក់បំណាច់សម្រាប់ផ្តល់ឲ្យអ្នកថែទាំជនរងគ្រោះក្នុងរយៈពេលសម្រាកនៅមន្ទីរពេទ្យ)
- **-តាវកាលិកបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន** (ប្រាក់បំណាច់សម្រាប់ផ្តល់ឲ្យជនរងគ្រោះដែលអាក់ខានធ្វើការងារ ចាប់ពី ២ ថ្ងៃឡើងទៅ)
- **-តាវកាលិកបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍** (ប្រាក់បំណាច់សម្រាប់ផ្តល់ឲ្យជនរងគ្រោះដែលខូចខាត ឬបាត់បង់ផ្នែកណាមួយនៃកាយសម្បទាជាអចិន្ត្រៃយ៍)
- **-តាវកាលិកឧត្តរជីវី** (ប្រាក់បំណាច់សម្រាប់ផ្តល់ឲ្យអ្នកនៅក្នុងបន្ទុកផ្ទាល់របស់ជនរងគ្រោះថ្នាក់ការងារបណ្តាលឲ្យបាត់បង់ជីវិត)
- **-វិភាជន៍បូជាសព** (ប្រាក់សម្រាប់ផ្តល់ឲ្យអ្នកដែលបានចំណាយសម្រាប់បូជាសព)
- **-តាវកាលិកអ្នកចាំថែរក្សា** (ប្រាក់បំណាច់សម្រាប់ផ្តល់ឲ្យអ្នកមើលថែជនរងគ្រោះបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ ដែលតម្រូវឲ្យមានអ្នកចាំមើលថែជាប្រចាំ)

បេឡាជាតិរបបសន្តិសុខសង្គមស្នើសុំលោក/លោកស្រី ជាម្ចាស់ ឬនាយក ឬតំណាងនៃសហគ្រាសគ្រឹះស្ថានជូនដំណឹងដល់កម្មករនិយោជិតរបស់ខ្លួនដែលបានទទួលរងគ្រោះថ្នាក់ការងារ និងសាមីជនរងគ្រោះថ្នាក់ការងារទាំងអស់ដែលពុំទាន់បានធ្វើការទាមទារតាវកាលិកណាមួយដូចបានជម្រាបជូនខាងលើនេះ មកបំពេញសំណុំបែបបទទាមទារតាវកាលិកនៅបេឡាជាតិរបបសន្តិសុខសង្គមឲ្យបានរួសរាន់។

បេឡាជាតិរបបសន្តិសុខសង្គមសង្ឃឹមយ៉ាងមុតមាំថាលោក/លោកស្រី និងបងប្អូនកម្មករនិយោជិតជាសាមីជនរងគ្រោះថ្នាក់ការងារទាំងអស់នឹងសហការ អនុវត្តតាមសេចក្តីជូនដំណឹងនេះប្រកបដោយប្រសិទ្ធភាពខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ ២០១៥

**នាយកបេឡាជាតិរបបសន្តិសុខសង្គម**

**អ៊ុក_សមវិទ្យា**


អាសយដ្ឋានអគារលេខ៣ មហាវិថីសហព័ន្ធរុស្សី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទៈ ០២៣-៨៨ ២៤ ៣៤,០២៣ ៩៩ ៨៤ ១៧ ០២៣-៩៩ ៨៤ ១៨ , ០២៣ ៩៩ ៨៤ ១៩
ទូរសារៈ ០២៣ ៨៨ ២៦ ២៣,ប្រអប់សំបុត្រ P.O Box 70
Website:www.nssf.gov.kh